ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ: ៧៤០ អគរ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលអត្រាពន្ធគយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ជាបណ្តោះអាសន្នលើមុខទំនិញសរសៃអំបោះសូត្រនាំចូល

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសេចក្តីរីករាយសូមប្រកាសជូនដំណឹងដល់សាធារណៈជនឲ្យបានជ្រាបថា នាថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កន្លងទៅនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញនូវប្រកាសលេខ ៥៤០ សហវ.ប្រក ស្តីពីការកែសម្រួលអត្រាពន្ធគយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋជាបណ្តោះអាសន្នលើមុខទំនិញសរសៃអំបោះសូត្រនាំចូល ។ តាមខ្លឹមសារនៃប្រកាសនេះ អត្រាពន្ធនាំចូលរបស់មុខទំនិញសរសៃអំបោះសូត្រ ត្រូវបានបញ្ចុះមកសូន្យភាគរយ (0%) ហើយដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ។ ការផ្តល់អត្រាពន្ធអនុគ្រោះនេះ គឺធ្វើឡើងដោយអនុលោមតាមលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៥ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ កន្លងទៅនេះ និងតាមសំណើលើកឡើងដោយសហប្រធានក្រុមការងារផ្នែកឯកជន ផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម ។ ការដាក់អាករលើតម្លៃបន្ថែមដូចខាងលើនេះ ធ្វើឡើងជាលក្ខណៈបណ្តោះអាសន្ន ដែលមានសុពលភាពអនុវត្តត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ ដើម្បីជាការត្រៀមបំរុងនូវវិធានការគាំពារដល់ផលិតកម្មសូត្រក្នុងស្រុកនាពេលខាងមុខ ។

អាស្រ័យហេតុនេះ សូមធុរជនពាក់ព័ន្ធទាំងអស់ជ្រាបជាព័ត៌មាន និងរួមចំណែកផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមការគួរ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

**បណ្ឌិត.ប៉ែន_ស៊ីម៉ន**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់សមាសភាពក្រុមការងារផ្នែកឯកជន ផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ E-mail customs@camnet.com.kh